រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ១៣ សសរ**

**ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង**

**ដើម្បីស្រាវជ្រាវត្រួតពិនិត្យប្រមូលពត៌មានជុំវិញបញ្ហាផ្សារម៉ែងឈូក**

**និងបញ្ហាដេញថ្លៃតាស៊ីស្តង់ត្រីស្រស់នៅខេត្តបាត់ដំបង**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- ផ្អែកតាមមតិណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី
- ផ្អែកតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដែលមានសមាសភាពដូច តទៅ :

១-លោក **កុល ទីរក្ស** តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២-ឯកឧត្តម **យិន គឹមស៊ាន** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាអនុប្រធាន

៣-លោក **ការ៉ង ឈាងខំណន** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៤-លោក **ហួត ទុន្នី** តំណាងក្រសួងយុត្តិធម៌ ជាសមាជិក

៥-លោក **ហួយ គឹមឡុន:** តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក **ស៊ុន សុខន** តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការដូចកំណត់ក្នុងប្រការមួយមានភារកិច្ចស្រាវជ្រាវ ត្រួតពិនិត្យប្រមូលពត៌មានសំរាប់ដាក់ជូន និង សុំសេចក្តីសំរេចដ៏ខ្ពង់ខ្ពស់ អំពីរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការមានសិទ្ធិចាត់តាំងក្រុមជំនួយការ ដើម្បីជួយសំរួលការងារក្នុងករណីចាំបាច់ ។

**ប្រការ ៤ :** គណៈកម្មការមានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និង អង្គភាពផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីបំពេញការងារអោយមានប្រសិទ្ធភាព ។

**ប្រការ ៥ :** រាល់មធ្យោបាយ និងថវិកាសំរាប់ធ្វើការក្នុងកិច្ចការនេះ សាមីក្រសួងនីមួយៗជាអ្នកទទួលបន្ទុក ដោះស្រាយដើម្បីអោយមន្ត្រីក្រោមឱវាទដែលមានឈ្មោះដូចក្នុងប្រការ១ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ការងារ ។

**ប្រការ ៦ :** សេចក្តីសំរេចណាដែលមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែល ពាក់ព័ន្ធ និងឯកឧត្តម អស់លោកដូចក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តតាមស្មារតីនៃសេចក្តីសំរេច នេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ស ខេង**

## III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

**ប្រកាសលេខ ១៦៥ ឧរថកឧ ខប្រក**

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com